# ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៩-១០-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១០០៤/០០២ ត្រូវបន្ថយទោសរយៈពេលទទួលរងទោស ឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនក្នុងរយៈពេលរងទោសក្នុងពន្ធនាគារ កន្លងមក ២៤៨៥

០៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៨ ស្ដីពីការតម្លើងឋានន្តរសក្ដិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្ដម **អ៊ី ឈាន** អភិបាលក្រុងប៉ៃលិន ២៤៩៨

០៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០០៩ ស្ដីពីការតែងតាំងឯកឧត្ដម **ម៉ិច ម៉ឿន** ជា **អនុរដ្ឋលេខាធិការ** ក្រសួងធម្មការ និងកិច្ចការសាសនា ជំនួសឯកឧត្ដម **ហ៊ុន ហេង** ដែលត្រូវបានទទួលតំណែងថ្មី ២៤៩៩

០៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១០ ស្ដីពីការតម្លើងឋានៈ ជូនទីប្រឹក្សាផ្ទាល់ និងនាយិកាពិធីការសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៥០០


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


០៦-១០-២០០៤ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្ដីពីការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សជីវ ចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្ដារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រ សត្វព្រៃខេត្តកោះកុង ២៥០២

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្ដីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥០៧

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥០៩

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្ដីពីការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ២៥១១

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្ដីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥១៣

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្ដីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥១៥

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥១៧

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្ដីពីការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥១៩

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥២១

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥២៣

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥២៥

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ស្តីពីការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥២៧

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥២៩

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៣១

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨០ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៣៣

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨១ អនក្រ.បក ស្តីពីការសំរួល ផ្ទេរ តែងតាំង និងប្រគល់ ភារកិច្ចជូនមន្ត្រីរាជការ ២៥៣៥

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨២ អនក្រ.បក ស្តីពីការសំរួល តែងតាំង និងប្រគល ភារកិច្ចជូនមន្ត្រីរាជការ ២៥៣៧

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.បក ស្តីពីការសំរួលមុខតំណែង និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ២៥៣៩

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៤អនក្រ.បក ស្តីពីការផ្ទេរតែងតាំងនិងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៤១

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៤៣

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.បក ស្តីពីការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៤៥

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៧ អនក្រ.បក ស្តីពីការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៤៧

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៨ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៤៩

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៨៩ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៥១

០៥-១១-២០០៤ -អនុក្រឹត្យលេខ ៥៩០ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៥៣

០៨-១១-២០០៤ -អនុក្រឹត្យលេខ ៥៩១ អនក្រ.បក ស្តីពីការជូនមេដាយការងារ ២៥៥៥

០៨-១១-២០០៤ -អនុក្រឹត្យលេខ ៥៩២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិក្រមសីលធម៌សំរាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស ២៥៥៧

## ២-សេចក្ដីសំរេច

០២-១១-២០០៤ -សេចក្ដីសំរេចលេខ ៦៧ សសរ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២៥៥៩

## III-ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

០៥-១១-២០០៤ -ប្រកាសលេខ ២៤២ បទ.ប្រក ស្ដីពីការកែសំរួលសមាសភាពមន្ត្រីរាជការគ្រប់គ្រងបណ្ដោះអាសន្នមាត់ច្រកទូរគមនាគមន៍ អន្តរជាតិ ២៥៦០

## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣២ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ក្រោលគោ ស្ថិតនៅក្នុងឃុំក្រោលគោ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ២៥៦៣

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៣ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ស្រីសិទ្ធិ ស្ថិតនៅក្នុងឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ ២៥៦៤

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៤ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ គីរីចុងកោះ ស្ថិតនៅក្នុងឃុំគីរីចុងកោះ ស្រុកគីរីវង់ ខេត្តតាកែវ ២៥៦៥

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៥ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ អង្គរបាន ស្ថិតនៅក្នុងឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ២៥៦៦

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៦ អយក.ប្រក ស្ដីពីការពង្រីកអនុវិទ្យាល័យ " ហ៊ុន សែន គរ " ទៅជាវិទ្យាល័យ " ហ៊ុន សែន គរ " ស្ថិតនៅក្នុងឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ២៥៦៧

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៧ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ទ្រមូង ស្ថិត នៅក្នុងឃុំព្រៃអំពក ស្រុកគីរីវង់ ខេត្តតាកែវ ២៥៦៨

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៨ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ទួលសាលា ស្ថិតនៅក្នុងឃុំជ្រុងពពេល ស្រុករំដួល ខេត្តស្វាយរៀង ២៥៦៩

០៤-១១-២០០៤ -ប្រកាសលេខ ១៤៣៩ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ព្រៃឈើទាល ស្ថិតនៅក្នុងឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ ២៥៧០

០៤-១១-២០០៤ -ប្រកាសលេខ ១៤៤០ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ជីកជី ស្ថិតនៅក្នុងឃុំអណ្ដូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ២៥៧១

០៤-១១-២០០៤ -ប្រកាសលេខ ១៤៤១ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ គគីរសោម ស្ថិតនៅក្នុងឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ២៥៧២

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-១១-២០០៤ -ប្រកាសលេខ ៤០០ សហវ.ពដ.ប្រក ស្តីពីការកែតម្រូវ នៃប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០០៤ ២៥៧៣

# ព្រះរាជក្រឹត្យ

នស/រកត/១០០៤/០០២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត០៧០៤/១២៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ធូរបន្ថយរយៈពេលទទួលរងទោសចំនួន ១២ខែ ឱ្យទណ្ឌិតចំនួន ៤នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១. ទណ្ឌិតឈ្មោះ ឯម សារ៉េត ហៅ កេត ភេទស្រី អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៩-៩៤ ពីបទមនុស្សឃាតដោយចេតនាមានអាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជាជន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមរំលេចសាលក្រមលេខ ០៨ ចុះថ្ងៃទី ០២-០២-៩៥ របស់តុលាការខេត្តកំពត ។

២. ទណ្ឌិតឈ្មោះ សែន សំខាន់ ហៅ ប្រាជ្ញ អាព ភេទប្រុស អាយុ ៣៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៥-៩៥ ពីបទមនុស្សឃាតដោយចេតនា និងកាន់កាប់អាវុធខុសច្បាប់ និងប្លន់យកទ្រព្យសម្បត្តិប្រជាជន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមរំលេចសាលក្រមលេខ៧៣ ចុះថ្ងៃទី ២៦-១០-៩៥ របស់តុលាការខេត្តព្រៃវែង ។

៣. ទណ្ឌិតឈ្មោះ **អ៊ំប្រ៊ិច អាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៩-៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-៩៥ របស់តុលាការខេត្តក្រចេះ ។

៤. ទណ្ឌិតឈ្មោះ **អ៊ំប្រ៊ិច ឆាន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៩-៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-៩៥ របស់តុលាការខេត្តក្រចេះ ។

**មាត្រា ២ :** ត្រូវបន្ធូរបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ ឱ្យទណ្ឌិតចំនួន ២៦នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១. ទណ្ឌិតឈ្មោះ **ខាត វ៉េន** ហៅ ខ្វេ ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១១-៩៥ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ២៩-០២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

២. ទណ្ឌិតឈ្មោះ **ឡើ សុភាព** ភេទប្រុស អាយុ ២៨ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-១០-៩៧ ពីបទពង្រត់មនុស្សយកទៅលក់ ធ្វើស្រីពេស្យា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ០៣ ចុះថ្ងៃទី ០៦-០១-៩៨ របស់តុលាការខេត្តបាត់ដំបង ។

៣. ទណ្ឌិតឈ្មោះ **លាម គឹន** ហៅ ធី ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-០១-៩៨ ពីបទធ្វើចរាចរក្រដាសប្រាក់ក្លែងក្លាយ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ ចុះថ្ងៃទី ២២-៤-៩៨ របស់តុលាការខេត្តបាត់ដំបង ។

៤. ទណ្ឌិតឈ្មោះ **ហ៊ិន សុផាត** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៧-៩៥ ពីបទប្លន់ និងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨០ ចុះថ្ងៃទី ២៣-១២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៥. ទណ្ឌិតឈ្មោះ **អ៊ុម អ៊ុន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៤-៩៧ ពីបទមនុស្សឃាតគិតទុកជាមុន និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ១៣-៦-៩៧ របស់តុលាការខេត្តបាត់ដំបង ។

៦. ទណ្ឌិតឈ្មោះ **ឆាត សុភី** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៣-៩៧ ពីបទមនុស្សឃាតគិតទុកជាមុន និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ

កំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ១៣-៦-៩៧ របស់តុលាការខេត្តបាត់ដំបង ។

**៧.** ទណ្ឌិតឈ្មោះ **យឹម ឌី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៣-៩៧ ពីបទមនុស្សឃាតគិតទុកជាមុន និងប្លន់ដោយប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ១៣-៦-៩៧ របស់តុលាការខេត្តបាត់ដំបង ។

**៨.** ទណ្ឌិតឈ្មោះ **ស៊ិន ហឿម** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៧-៩៩ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩៣ ចុះថ្ងៃទី ០៦-១២-៩៩ របស់តុលាការខេត្តបាត់ដំបង ។

**៩.** ទណ្ឌិតឈ្មោះ **ទ្រី ប៊ុះ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-០១-៩៩ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ ចុះថ្ងៃទី ២៨-៣-៩៩ របស់តុលាការខេត្តបាត់ដំបង ។

**១០.** ទណ្ឌិតឈ្មោះ **ជាន ម៉ាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-១១-៩៩ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៣៧២ ចុះថ្ងៃទី ២១-១២-៩៩ របស់តុលាការខេត្តបាត់ដំបង ។

**១១.** ទណ្ឌិតឈ្មោះ **ម៉ែន ចាន់នី** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៥-៩៦ ពីបទធ្វើមនុស្សឃាតដោយចេតនា និងគិតទុកជាមុន ហើយត្រូវតុលាការសំរេច ផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ១១-១០-៩៦ របស់តុលាការខេត្តកំពត ។

**១២.** ទណ្ឌិតឈ្មោះ **កែវ សុភ័ក្រ្ត** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-០១-៩៧ ពីបទប្លន់ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ១៩-៩-៩៧ របស់តុលាការខេត្តកោះកុង ។

**១៣.** ទណ្ឌិតឈ្មោះ **ចក់ ចេន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១២-៩៥ ពីបទប្លន់ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ២៨-៦-៩៦ របស់តុលាការខេត្តកោះកុង ។

**១៤.** ទណ្ឌិតឈ្មោះ **សែត សារឿន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-៤-៩៨ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦១"ត" ចុះថ្ងៃទី ២៥-៩-៩៨ របស់តុលាការខេត្តកំពង់ចាម ។

**១៥.** ទណ្ឌិតឈ្មោះ **ម៉ុត ឌុល** ភេទប្រុស អាយុ ៥៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៧-៩៩ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ០៩-០២-៩៩ របស់តុលាការខេត្តព្រៃវែង ។

**១៦.** ទណ្ឌិតឈ្មោះ **ខន់ សារឿន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៤-៩៥ ពីបទប្លន់ និងប៉ុនប៉ងសម្លាប់មនុស្ស ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ១៦-៨-៩៥ របស់តុលាការខេត្តព្រៃវែង ។

**១៧.** ទណ្ឌិតឈ្មោះ **មិន ម៉ៅ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៩-៩៩ ពីបទប៉ុនប៉ងសំលាប់ និងប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៧ ចុះថ្ងៃទី ៨-១១-៩៩ របស់តុលាការខេត្តក្រចេះ ។

**១៨.** ទណ្ឌិតឈ្មោះ **សោម ធ្នី** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១២-៩៩ ពីបទប្លន់ចាប់ជំរិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១១-៤-២០០០ របស់តុលាការខេត្តក្រចេះ ។

**១៩.** ទណ្ឌិតឈ្មោះ **ឆេង សុខលី** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១២-៩៩ ពីបទប្លន់ចាប់ជំរិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១១-៤-២០០០ របស់តុលាការខេត្តក្រចេះ ។

**២០.** ទណ្ឌិតឈ្មោះ **នុំ សាន** ហៅ ស្មិត ភេទប្រុស អាយុ ២១ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៩-៦-២០០០ ពីបទប៉ុនប៉ងមនុស្សឃាត និងប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ២២-៦-២០០០ របស់តុលាការខេត្ត ក្រចេះ ។

**២១.** ទណ្ឌិតឈ្មោះ **ឃិន ភាព** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-៩៧ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ៣៣ ចុះថ្ងៃទី ០២-៩-៩៧ របស់តុលាការខេត្តក្រចេះ ។

**២២.** ទណ្ឌិតឈ្មោះ **អៀម ខៅល** ភេទប្រុស អាយុ ៣០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-៩៧ ពីបទប្លន់ប្រដាប់អាវុធហើយ ត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៣ឆ្នាំ តាមអំណាចសាលក្រមលេខ៣៣ ចុះថ្ងៃទី ០២-៩-៩៧ របស់តុលាការខេត្តក្រចេះ ។

**២៣.** ទណ្ឌិតឈ្មោះ **ស្រាក់ សិដ្ឋ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៧-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ១៦-៧-៩៨ របស់តុលាការខេត្តក្រចេះ ។

**២៤.** ទណ្ឌិតឈ្មោះ **គួន សារី** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-១០-៩៨ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២២-៣-៩៩ របស់តុលាការខេត្តក្រចេះ ។

**២៥.** ទណ្ឌិតឈ្មោះ **ស៊ាន អេន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១០-២០០០ ពីបទប្លន់ និងប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ០៦ ចុះថ្ងៃទី ១២-០២-២០០១ របស់តុលាការខេត្តក្រចេះ ។

**២៦.** ទណ្ឌិតឈ្មោះ **លី ឈន** ភេទស្រី អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១០-២០០០ ពីបទធ្វើអាជីវកម្មលើមនុស្ស ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២១-៣-២០០១ របស់តុលាការខេត្តក្រចេះ ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ ឱ្យទណ្ឌិតចំនួន ៤១នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

**១.** ទណ្ឌិតឈ្មោះ **គីម ឆ៊ាទ** ភេទប្រុស អាយុ ២២ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-០២-៩៩ ពីបទសមគំនិតក្នុងអំពើឃាតកម្មហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦៧ ចុះថ្ងៃទី ១៣-៧-៩៩ របស់តុលាការខេត្តបាត់ដំបង ។

**២.** ទណ្ឌិតឈ្មោះ **អ៊ុខ សាខ** ភេទប្រុស អាយុ ៤២ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៩-៩៧ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៥ ចុះថ្ងៃទី ២២-១២-៩៧ របស់តុលាការខេត្តបាត់ដំបង ។

**៣.** ទណ្ឌិតឈ្មោះ **ស៊ឹម ថុន** ហៅ ថានភេទប្រុស អាយុ ៤១ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-១២-៩៨ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៣ ចុះថ្ងៃទី ១១-៦-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៤. ទណ្ឌិតឈ្មោះ **សន ថា** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-៩៩ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣១ ចុះថ្ងៃទី ០៦-១១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៥. ទណ្ឌិតឈ្មោះ **កែវ សារិន** ភេទប្រុស អាយុ ៣៨ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៥-២០០១ ពីបទក្រុមជនប្រដាប់អាវុធ សមគំនិតប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ៦៥"ខ" ចុះថ្ងៃទី ១៣-១១-២០០១ របស់តុលាការខេត្តបាត់ដំបង ។

៦. ទណ្ឌិតឈ្មោះ **ចាន់ ស្មី** ហៅ ម៉ៅ ហៅ ធី ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៧-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩៧ ចុះថ្ងៃទី ១៣-៩-២០០១ របស់តុលាការខេត្តបាត់ដំបង ។

៧. ទណ្ឌិតឈ្មោះ **យ៉េម រ៉ា** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៧-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១៤-៣-២០០០ របស់តុលាការខេត្តបាត់ដំបង ។

៨. ទណ្ឌិតឈ្មោះ **ខៀវ បុញ** ភេទប្រុស អាយុ ១៨ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-០៩-៩៩ពីបទសមគំនិតអំពើឃាតកម្មហើយ ត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦៧ ចុះថ្ងៃទី ១៣-៧-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៩. ទណ្ឌិតឈ្មោះ **ខៀត សុភាព** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១០-៩៦ ពីបទក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ២៥១ ចុះថ្ងៃទី ១២-១២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

១០. ទណ្ឌិតឈ្មោះ **ចាន់ ម៉ុនថេត** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៨-១២-៩៨ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាច សាលក្រមលេខ ១០១ ចុះថ្ងៃទី ១១-៥-៩៩ របស់តុលាការខេត្តបាត់ដំបង ។

១១. ទណ្ឌិតឈ្មោះ **លន់ លីន** ភេទស្រី អាយុ ១៥ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៨-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រហើយត្រូវតុលាការសំរេចផ្តន្ទាទោស

ដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមសាលក្រមលេខ៣៦៩ ចុះថ្ងៃទី ១៤-១១-២០០០ របស់តុលាការខេត្តបាត់ដំបង ។

**១២.** ទណ្ឌិតឈ្មោះ **តែ រី** ភេទប្រុស អាយុ ៣៥ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-០១-៩៩ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំតាមសាលក្រមលេខ ៧៩ ចុះថ្ងៃទី ០៧-៤-៩៩ របស់តុលាការខេត្ត បាត់ដំបង ។

**១៣.** ទណ្ឌិតឈ្មោះ **ទ័ន តុន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៥-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមសាលក្រមលេខ ៣៨៩ ចុះថ្ងៃទី ០១-១២-២០០០ របស់តុលាការខេត្តបាត់ដំបង ។

**១៤.** ទណ្ឌិតឈ្មោះ **សែ សុត** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១២-៩៩ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមសាលក្រមលេខ ៤២ ចុះថ្ងៃទី ២៣-០២-៩៩ របស់តុលាការខេត្តបាត់ដំបង ។

**១៥.** ទណ្ឌិតឈ្មោះ **មើត ចាន់ថន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-១០-២០០០ ពីបទប៉ុនប៉ងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមសាលក្រមលេខ ០១"គ" ចុះថ្ងៃទី ០៣-០១-២០០១ របស់តុលាការខេត្តបាត់ដំបង ។

**១៦.** ទណ្ឌិតឈ្មោះ **ឈឹម សារ៉េត** ហៅ កង យ៉ន ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-៨-២០០១ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងកាន់កាប់អាវុធដោយខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ ៦ខែ តាមសាលក្រមលេខ២៧ ចុះថ្ងៃទី ២៦-៣-២០០២ របស់តុលាការខេត្តកំពត ។

**១៧.** ទណ្ឌិតឈ្មោះ **ជៀល ចាន់ឌី** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៧-៩៧ ពីបទប៉ុនប៉ងសម្លាប់មនុស្ស និងបង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមសាលក្រមលេខ ៤១ ចុះថ្ងៃទី ២៦-១១-៩៧ របស់តុលាការខេត្តកោះកុង ។

**១៨.** ទណ្ឌិតឈ្មោះ **ចាន់ ធី** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៨-៩៨ ពីបទអំពើមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមសាលក្រមលេខ ០១ ចុះថ្ងៃទី ១៨-០១-៩៩ របស់តុលាការខេត្តកោះកុង ។

**១៩**.ទណ្ឌិតឈ្មោះ **ហ៊ិន ឆា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៨-៩៨ ពីបទអំពើហេដកម្មពិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមសាលក្រមលេខ ០១ ចុះថ្ងៃទី ១៨-០១-៩៩ របស់តុលាការខេត្តកោះកុង ។

**២០**.ទណ្ឌិតឈ្មោះ **ឡុង ស៊ី** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៥-២០០១ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមសាលក្រមលេខ ១៧ ចុះថ្ងៃទី ១៥-៧-៥៩ របស់តុលាការខេត្តស្ទឹងត្រែង ។

**២១**.ទណ្ឌិតឈ្មោះ **ខៀវ សារត** ហៅ កែវ កុសល ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-១០-២០០០ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមសាលក្រមលេខ ២១ ចុះថ្ងៃទី ២៤-៥-២០០១ និងលេខ ២២ ចុះថ្ងៃទី ២៤-៥-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

**២២**. ទណ្ឌិតឈ្មោះ **សុខ ឥល្លី** ហៅ ជា វុទ្ធី ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៥-២០០១ ពីបទប្លន់ប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមសាលក្រមលេខ ៣៧ ចុះថ្ងៃទី ០៣-១២-២០០១ របស់តុលាការ ខេត្តស្ទឹងត្រែង ។

**២៣**. ទណ្ឌិតឈ្មោះ **ខាន់ រ៉ាទី** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៦-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមសាលក្រមលេខ ១៩ ចុះថ្ងៃទី ២៥-១១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

**២៤**. ទណ្ឌិតឈ្មោះ **ទ៉ាន់ ឌិន** ភេទប្រុស អាយុ ៥០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៧-៩៩ ពីបទចោរកម្ម និងប្រើប្រាស់ត្រាក្លែងក្លាយ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមសាលក្រមលេខ ០៦ ចុះថ្ងៃទី ១៧-២-២០០០ របស់តុលាការខេត្តស្ទឹងត្រែង ។

**២៥**.ទណ្ឌិតឈ្មោះ **លី ខាន់** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៣-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមសាលក្រមលេខ ៣៣ ចុះថ្ងៃទី ១៤-៩-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

**២៦**.ទណ្ឌិតឈ្មោះ **អឿន ខា** ហៅ យ៉ន ខា ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី២៧-៣-២០០១ ពីបទចាប់មនុស្សជំរិតយកប្រាក់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមសាលក្រមលេខ១២៥"ក" ចុះថ្ងៃទី២២-៨-២០០១ របស់តុលាការ ខេត្ត កំពង់ចាម ។

២៧_ ទណ្ឌិតឈ្មោះ **រ៉ឹយ ថា** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១១-២០០០ ពីបទចាប់មនុស្សជំរិតយកប្រាក់ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦"ក" ចុះថ្ងៃទី ៩-៥-២០០១ របស់តុលាការខេត្តកំពង់ចាម ។

២៨_ ទណ្ឌិតឈ្មោះ **ហ៊ិន តឿ** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-០២-២០០១ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៣ ចុះថ្ងៃទី ២២-៨-២០០១ របស់តុលាការខេត្តព្រៃវែង ។

២៩_ ទណ្ឌិតឈ្មោះ **ញ៉ាញ់ រដ្ឋ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៦-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៨ ចុះថ្ងៃទី ១៥-១២-២០០០ របស់តុលាការខេត្តព្រៃវែង ។

៣០_ ទណ្ឌិតឈ្មោះ **អ៊ុម ហាំ** ភេទប្រុស អាយុ ៦៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៨-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ២០-០២-២០០១ របស់តុលាការខេត្តព្រៃវែង ។

៣១_ ទណ្ឌិតឈ្មោះ **ហម ហាន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-១១-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ២៥-៤-២០០១ របស់តុលាការខេត្តព្រៃវែង ។

៣២_ ទណ្ឌិតឈ្មោះ **យី ស** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ២៧-៦-២០០១ របស់តុលាការខេត្តព្រៃវែង ។

៣៣_ ទណ្ឌិតឈ្មោះ **ថាំ ណន់** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០១-២០០២ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជន ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ០៧-០៥-២០០២ របស់តុលាការខេត្តព្រៃវែង ។

៣៤_ ទណ្ឌិតឈ្មោះ **សុខ ឌុល** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៧-៩៩ ពីបទប្លន់ប្រដាប់អាវុធ បង្ករបួសស្នាម និងលាក់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២៦-០១-២០០០ របស់តុលាការខេត្តក្រចេះ ។

**៣៥.** ទណ្ឌិតឈ្មោះ **ជឹម សុផល** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៣-២០០២ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៧ ចុះថ្ងៃទី ០៣-៩-២០០២ របស់តុលាការខេត្តក្រចេះ ។

**៣៦.** ទណ្ឌិតឈ្មោះ **មេត ភុល** ភេទប្រុស អាយុ ១៧ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៧-២០០១ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី ១៣-៩-២០០១ របស់តុលាការខេត្តក្រចេះ ។

**៣៧.** ទណ្ឌិតឈ្មោះ **កេវ មុន្នា** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៧-២០០១ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ២៤-០១-២០០០ របស់តុលាការខេត្តក្រចេះ ។

**៣៨.** ទណ្ឌិតឈ្មោះ **យឹម ម៉ារិទ្ធ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៨-២០០០ ពីបទប៉ុនប៉ងផ្តាច់ជីវិតគ្នា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ០៥-៥-២០០៣ របស់តុលាការខេត្តក្រចេះ ។

**៣៩.** ទណ្ឌិតឈ្មោះ **ឆាន់ ឡុងឌី** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃាត់ខ្លួននៅថ្ងៃទី ២៩-៣-២០០៣ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ ចុះថ្ងៃទី ២១-៨-២០០៣ របស់តុលាការខេត្តក្រចេះ ។

**៤០.** ទណ្ឌិតឈ្មោះ **ឈិត រិទ្ធី** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៥-២០០៣ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី ០២-១០-២០០៣ របស់តុលាការខេត្តក្រចេះ ។

**៤១.** ទណ្ឌិតឈ្មោះ **សន ឌី** ភេទប្រុស អាយុ ៤០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៦-២០០៣ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ០២"ង" ចុះថ្ងៃទី ០៩-១០-២០០៤ របស់តុលាការក្រុងភ្នំពេញ ។

**មាត្រា ៤ :** ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ១៧នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

**១.** ទណ្ឌិតឈ្មោះ **សូ រ័ត្ន** ភេទស្រី អាយុ ៥១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-០១-២០០១ ពីបទប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ២៥-៦-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

២. ទណ្ឌិតឈ្មោះ **នុប សុវណ្ណ** ហៅ រ៉ា ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១ ០២-៩៨ ពីបទប្លន់សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមរំលេចសាលក្រមលេខ ០៤ ចុះថ្ងៃទី ២៦ ៤ ៩៨ របស់តុលាការខេត្តស្ទឹងត្រែង ។

៣. ទណ្ឌិតឈ្មោះ **ស ពៅ** ភេទស្រី អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-១១ ៩៧ ពីបទជួញដូរមនុស្សយកទៅលក់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមរំលេចសាលក្រមលេខ ៤២ ចុះថ្ងៃទី ១៥-១២-៩៧ របស់តុលាការខេត្តស្ទឹងត្រែង ។

៤. ទណ្ឌិតឈ្មោះ **ស៊ុន សេត** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០២-២០០១ ពីបទប្លន់ប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមរំលេចសាលក្រមលេខ ៣០ ចុះថ្ងៃទី ១៧-៨-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

៥. ទណ្ឌិតឈ្មោះ **ស ឃុយ** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-០១-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ៥ឆ្នាំ តាមរំលេចសាលក្រមលេខ ៤៧"ក" ចុះថ្ងៃទី ៦-៤-២០០០ របស់តុលាការខេត្តកំពង់ចាម ។

៦. ទណ្ឌិតឈ្មោះ **លឹម ឆេងហ៊ន់** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៦-១០ ២០០០ ពីបទប៉ុនប៉ងធ្វើមនុស្សឃាដ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមរំលេចសាលក្រមលេខ ២១"ក" ចុះថ្ងៃទី ២៧ ២ ២០០១ របស់តុលាការខេត្តកំពង់ចាម ។

៧. ទណ្ឌិតឈ្មោះ **ម៉ែន រ៉ូ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥ ០១-៩៥ ពីបទចាប់រំលោភកុមារីសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមរំលេចសាលក្រមលេខ ២៧ ចុះថ្ងៃទី ០៨-៤-៩៦ របស់តុលាការខេត្តក្រចេះ ។

៨. ទណ្ឌិតឈ្មោះ **ឃួន សារឿន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១១-៩៧ ពីបទប៉ុនប៉ងធ្វើមនុស្សឃាដគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមរំលេចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៣-៤-៩៨ របស់តុលាការខេត្តក្រចេះ ។

៩. ទណ្ឌិតឈ្មោះ **ឡាយ អ៊ិត** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៣-៩៦ ពីបទធ្វើមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមរំលេចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១១-៦-៩៦ របស់តុលាការខេត្តក្រចេះ ។

**១០**_ ទណ្ឌិតឈ្មោះ **នួច ផន** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៧-៩៩ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ និងចូលរួមបង្កើតសកម្មភាពជាមួយក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំរោយសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តក្រចេះ ។

**១១**_ ទណ្ឌិតឈ្មោះ **ហុម ផល្លី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-០២-២០០០ ពីបទលួចទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការ សំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំរោយសាលក្រមលេខ ៤៤ ចុះថ្ងៃទី ១០-៥-២០០០ របស់តុលាការខេត្តក្រចេះ ។

**១២**_ ទណ្ឌិតឈ្មោះ **សៅ ទៀម** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៨-២០០០ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំរោយសាលក្រមលេខ ០១ ចុះថ្ងៃទី ០៥-០១-២០០១ របស់តុលាការខេត្តក្រចេះ ។

**១៣**_ ទណ្ឌិតឈ្មោះ **ខៀវ សុខណា** ភេទប្រុស អាយុ ២៦ ឆ្នាំត្រូវចាប់ខ្លួននៅថ្ងៃទី១១-៦-២០០២ ពីបទឃាតកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំរោយសាលក្រមលេខ ១០២ ចុះថ្ងៃទី ២៦-១២-២០០២ របស់តុលាការខេត្តក្រចេះ ។

**១៤**_ ទណ្ឌិតឈ្មោះ **គវិន ស៊ីថាន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-១០-២០០០ ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំរោយសាលក្រមលេខ ៥៤"ញ" ចុះថ្ងៃទី ១៥-៨-២០០១ និងសាលក្រមលេខ ២៥"រ" ចុះថ្ងៃទី ០៥-៤-២០០២ របស់តុលាការក្រុងភ្នំពេញ ។

**១៥**_ ទណ្ឌិតឈ្មោះ **សូ សាឡុន** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-០២-២០០២ ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំរោយសាលក្រមលេខ ៤៥"ដ" ចុះថ្ងៃទី ០៧-៨-២០០២ និងរបស់តុលាការក្រុងភ្នំពេញ ។

**១៦**_ ទណ្ឌិតឈ្មោះ **ឈាន នេនៈ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៧-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ៥ឆ្នាំ តាមអំរោយសាលក្រមលេខ ០២"ង" ចុះថ្ងៃទី ១៨-០១-២០០២ និងរបស់តុលាការក្រុងភ្នំពេញ ។

**១៧**_ ទណ្ឌិតឈ្មោះ **អន្ត អស្សេរិទ្ធ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៨-៥-

១៩៩៣ ពីបទអំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមសាលក្រមលេខ ៥៤ ចុះថ្ងៃទី ២៨-១២-៩៤ របស់តុលាការខេត្តកោះកុង ។

មាត្រា ៥ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧ល.០៤១០.០០២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ ២១៧៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ វិច្ឆិកា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០០៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរសក្តិ ថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តម អ៊ី ឈាន អត្តលេខ ០០៣៨០៤ អភិបាលក្រុងប៉ៃលិន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពាស.០៤១១.០០៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខៈ ៥៦៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ម៉ិច ហឿន ជា **អនុរដ្ឋលេខាធិការ** ក្រសួងធម្មការ និងសាសនា ជំនួសឯកឧត្តម ហ៊ិន ហេង ដែលត្រូវបានទទួលតំណែងថ្មី ។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រស.០៤១១.០០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ: [illegible] ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានៈ ជូនទីប្រឹក្សាផ្ទាល់ និងនាយិកាពិធីការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឡូង រតនា** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **ហ៊ុយ ពិសិដ្ឋ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៣- ឯកឧត្តម **គង គេង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៤- ឯកឧត្តម **ស៊ាន បូរ៉ាត** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៥- ឯកឧត្តម **ទី សុគន្ធ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **រដ្ឋលេខាធិការ**

៦- ឯកឧត្តម **ហ៊ឹម ស្មឿត** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៧- ឯកឧត្តម **ម៉ើន រុន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៨- ឯកឧត្តម **សួន រចនា** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ**

៩- ឯកឧត្តម យី ជន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ

១០- ឯកឧត្តម គង់ អៀង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ រដ្ឋលេខាធិការ

១១- ឯកឧត្តម ឈួន សុធី ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ រដ្ឋលេខាធិការ

១២- លោកជំទាវ សុខឡេង បូរ៉ា នាយិកាពិធីការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/១១០៤/៧១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខ ៤៧៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០០៤

រដ្ឋលេខាធិការរាជរដ្ឋាភិបាល

ឈាង ឆាន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/០៧ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤

# ស ម្រេ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និង មជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់ លក្ខណៈ ជីវសាស្ត្រសត្វព្រៃ ខេត្តកោះកុងក្នុងគោលបំណង÷

-ការពារ និង អភិរក្សរុក្ខជាតិព្រៃឈើ និង សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និង ប្រភេទជិតផុតពូជ

-ការពារច្រករបៀងសត្វដំរីក្នុងភូមិភាគនិរតីនៃប្រទេសកម្ពុជា

-រៀបចំស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃ

-រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជម្រកសម្រាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ

-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍន៍ និង អភិរក្សជីជំរាល និង ជីវចំរុះ

-ការពារការហូរច្រោះ ទឹកជំនន់ ជីជាតិរបស់ដី រក្សានូវនិយតភាពនៃប្រភពទឹក និង គុណភាពទឹក

-ជំរុញការអប់រំ ផ្សព្វផ្សាយ និង អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ

-រួមចំណែកថែរក្សាកេរ្តិ៍ដំណែលវប្បធម៌ប្រវត្តិសាស្ត្រ និងអភិវឌ្ឍន៍ វិស័យទេសចរណ៍ធម្មជាតិក្នុងតំបន់។

**មាត្រា ២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការរៀបចំ និង គ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និង មជ្ឈមណ្ឌលស្តារលទ្ធភាព ដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃ ខេត្តកោះកុងដោយសហការជាមួយក្រសួងពាក់ព័ន្ធ និង បង្កើតតំបន់អភិវឌ្ឍន៍កសិកម្មដែលផ្តល់ប្រយោជន៍ដល់សហគមន៍ មូលដ្ឋានប្រកបដោយនិរន្តរភាព។

**មាត្រា ៣.-**

ដំណើរការនៃការរៀបចំ និង ការគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី២
## វិសាលភាព

មាត្រា ៤.-

- តំបន់ព្រៃការពារ សម្រាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៉ា និង បជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង មានផ្ទៃក្រឡា ១៤៤ ២៧៥ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា: A(334074, 1237322) B (333958, 1251538) C(340637, 1253405) D (338380, 1273232) E (326516, 1273260) F (320548, 1278873) G (314321, 1290020) H (309322, 1286590) I (291133, 1296529) J (280058, 1284999) K (283977, 1284463) L (287514, 1283233) M (289023, 1280539) N (297890, 1269927) O (306462, 1258808).

- ការកែប្រែផ្ទៃក្រឡាតំបន់ព្រៃការពារសម្រាប់អភិរក្សជីវចំរុះការពារច្រករបៀងសត្វជីវ៉ា និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុងនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## ការហាមឃាត់

**មាត្រា ៥.-**

សកម្មភាពគំរាមកំហែងដល់តំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វជីវ៉ា និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង ដូចខាងក្រោមត្រូវហាមឃាត់ដាច់ខាត:

-ការកែច្នៃផល អនុផលព្រៃឈើ ឬ ការបង្កើត និងដំណើរការមូលដ្ឋានឧស្សាហកម្ម សិប្បកម្មផ្សេងៗ និង ឡគ្រប់ប្រភេទ

-ការគាស់កកាយរករ៉ែ យកថ្មាំងសិលាដុតយកកំបោរ ឬ ធ្យូង ឬ គាស់កកាយដីប្រាប

-ការប្រមូលផល អនុផលព្រៃឈើ និងសកម្មភាពបរបាញ់ ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ព្រៃឈើ និង សត្វព្រៃគ្រប់ប្រភេទ

-ការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ និងការតាំងលំនៅដ្ឋានថ្មី ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

មាត្រា ៦.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិសាត់ និង អភិបាលខេត្តកំពង់ស្ពឺត្រូវ អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ


(291138,1296528)
(314321, 1290020)
(320548, 1278873)
(326516, 1273260)
(338380, 1273232)
(297890, 1269927)
(306462,1258808)
(334074, 1237322)
(289023, 1280539)
(280058, 1284999)
COORDINATE SYSTEM
Projection UTM
Zone 48
Horizontal Datum Indian 1960
Spheroid Everest
UTM Grid 5 Kilometers
Scale 1:350,000
10Km
N

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៦៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .-**

ត្រូវបានផ្ទេរភារកិច្ចលោក **សេង តុង** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាលរង ក្រុងភ្នំពេញ ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ២ .—**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៣រូប ជាអភិបាលរងក្រុង ដូចមានរាយនាមខាងក្រោម :

១- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ តានុរ័ត្ន** មន្ត្រីក្របខ័ណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ អោយមកទទួលភារកិច្ចជាអភិបាលរង ក្រុងភ្នំពេញ

២- លោក **អ៊ុច ចេវឧសេខ** អោយមកទទួលភារកិច្ចជាអភិបាលរង ក្រុងភ្នំពេញ

៣- លោក **ខួន ស៊ា** អោយមកទទួលភារកិច្ចជា អភិបាលរង ក្រុងភ្នំពេញ

**មាត្រា ៣ .—**

សាមីខ្លួន ដែលមានឈ្មោះក្នុង **មាត្រា២**ខាងលើ ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ សាមីខ្លួន ដែលពុំស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] វិច្ឆិកា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥៦៨ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរងខេត្ត ដូចមានរាយនាមខាងក្រោម :

១- លោក **សេង សៀកហ៊ុយ** មន្ត្រីក្របខ័ណ្ឌក្រសួងពត៌មាន ឱ្យមកទទួលភារកិច្ចជា អភិបាលរងទី២ ខេត្តកណ្តាល

២- លោក **នន សុត្ថា** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ៦ ឱ្យទទួលភារកិច្ចជា អភិបាលរង ខេត្តកណ្តាល ។

**មាត្រា ២ .–**

សាមីខ្លួន ដែលមានឈ្មោះក្នុង **មាត្រា១**ខាងលើ ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្រប តាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ .–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .–**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

ត្រូវបានផ្ទេរភារកិច្ចអភិបាលរងខេត្តបាត់ដំបង ចំនួន ០២រូប ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ដូចមានរាយនាមខាងក្រោម :

១- លោក **ទ្រាក់ ឡឿន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៥

២- លោក **សាន់ ឃឿប** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០

**មាត្រា ២ .—**

ត្រូវបានតែងតាំងមុខតំណែងលោក **ញ៉ិក គិមឈុន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៦ ជាអភិបាលរងទី១ ខេត្តបាត់ដំបង ។

**មាត្រា ៣ .—**

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរងខេត្ត ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ុយ ម៉ិនហេង** អោយមកទទួលភារកិច្ចជា អភិបាលរងទី៣ ខេត្តបាត់ដំបង

២- លោក **ស៊ូ អាវ៉ាហ្វាត់** មន្ត្រីក្របខ័ណ្ឌក្រសួងបរិស្ថាន អោយមកទទួលភារកិច្ចជា អភិបាលរងខេត្តបាត់ដំបង ។

**មាត្រា ៤ .—**

សាមីខ្លួន ដែលមានឈ្មោះក្នុង **មាត្រា៣**ខាងលើ ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ សាមីខ្លួន ដែលពុំស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៥ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .—**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៦ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧០ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១ .—**

